ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ......០០៧..ប.ទ..សជណ.........

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពង្រឹងគុណភាពសេវាទូរសព្ទចល័ត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ ឱ្យបានជ្រាបថា ពាក់ព័ន្ធនឹងភាពអាក់អួលនៃសេវាទូរសព្ទចល័តនៅតាមតំបន់មួយចំនួន ក្រសួងបានចាត់តាំងឱ្យក្រុមការងារនៃនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) ចុះត្រួតពិនិត្យគុណភាពសេវាទូរសព្ទឡើងវិញ ដើម្បីជំរុញឱ្យប្រតិបត្តិករទូរសព្ទចល័តទាំងអស់ពង្រឹងគុណភាពសេវារបស់ខ្លួនឱ្យបានល្អតាមរយៈការបំពាក់ឧបករណ៍ និងការសាងសង់បង្គោលអង់តែនបន្ថែម។ ប៉ុន្តែកន្លងមក ការតម្លើងបង្គោលអង់តែននេះក៏មានឧបសគ្គមួយចំនួន ដែលកើតចេញពីការព្រួយបារម្ភរបស់សាធារណជន លើផលប៉ះពាល់ផ្សេងៗ ដូចជារន្ទះ ការបាក់រលំ ជាពិសេសការបារម្ភលើផលប៉ះពាល់សុខភាពពីការសាយភាយរលកអាកាសវិទ្យុដោយយល់ច្រឡំថា ជាប្រភេទរលកវិទ្យុសកម្មទៅវិញ។

សភាពការណ៍បច្ចុប្បន្ន ប្រជាពលរដ្ឋត្រូវការសេវាទូរសព្ទនិងសេវាអ៊ីនធឺណិតកាន់តែខ្លាំង ជាពិសេសពាក់ព័ន្ធនឹងការរៀនតាមអនឡាញ (Online) ដោយប្រព័ន្ធបច្ចេកវិទ្យាទាប់រហ័សដែលធានានូវគុណភាព ដើម្បីបម្រើឱ្យគោលដៅនៃការអភិវឌ្ឍចំពោះមុខ។ ក្នុងន័យនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមអំពាវនាវនិងធ្វើការណែនាំដូចខាងក្រោម៖

១. ប្រតិបត្តិករទូរគមនាគមន៍ចល័តទាំងអស់ត្រូវពង្រឹងគុណភាពសេវាទូរសព្ទរបស់ខ្លួននៅគ្រប់ទីកន្លែង ជាពិសេសនៅតាមទីប្រជុំជន និងតំបន់អភិវឌ្ឍន៍ថ្មីៗ ដោយបំពាក់ឧបករណ៍ផ្តល់សេវា ឬសាងសង់បង្គោលអង់តែនបន្ថែមទៀត ជាកំហិត។ ក្រសួងសូមបញ្ជាក់យ៉ាងម៉ឺងម៉ាត់ថាប្រតិបត្តិករទូរគមនាគមន៍ត្រូវធានាលើគុណភាពសេវាទូរសព្ទចល័តជូនអ្នកប្រើប្រាស់ស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណរបស់ខ្លួន។ រាល់ការផ្តល់សេវាទូរសព្ទចល័តដែលមិនមានគុណភាព គឺជាអំពើមិនសុចរិត ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

២. តាមរយៈការសិក្សាស្រាវជ្រាវ គ្រប់ក្រុមហ៊ុនផ្តល់សេវាទូរសព្ទទាំងអស់បានប្រើប្រាស់ឧបករណ៍ស្របតាមស្តង់ដាររបស់សហភាពទូរគមនាគមន៍អន្តរជាតិ(ITU)ហើយ។ បច្ចុប្បន្ននេះ អង្គការសុខភាពពិភពលោក (WHO) មិនមានការរកឃើញផលប៉ះពាល់ជាក់លាក់ណាមួយដល់សុខភាពដែលបណ្តាលមកពីស្ថានីយ៍អង់តែនទូរសព្ទចល័ត ពីព្រោះរលកអាកាសវិទ្យុដែលប្រើប្រាស់ក្នុងប្រព័ន្ធទូរសព្ទចល័តមិនមែនជាប្រភេទរលកវិទ្យុសកម្មទេ។ បន្ថែមលើនេះទៀត នៅលើបង្គោលនីមួយៗក៏មានភ្ជាប់នូវឧបករណ៍ការពាររន្ទះផងដែរ។ ក្នុងន័យនេះ ក្រសួងសូមអំពាវនាវឱ្យប្រជាពលរដ្ឋមេត្តាផ្តល់កិច្ចសហការក្នុងការសាងសង់បង្គោលអង់តែននៅក្នុងតំបន់ដែលខ្លួនរស់នៅ ទន្ទឹមនឹងនេះ ក្រសួងនឹងជំរុញឱ្យនិយ័តករទូរគមនាគមន៍កម្ពុជា បន្តត្រួតពិនិត្យដោយយកចិត្តទុកដាក់និងការទទួលខុសត្រូវខ្ពស់បំផុត ដើម្បីធានាថាសេវាទូរសព្ទមានគុណភាព និងឧបករណ៍ទាំងអស់ស្របតាមស្តង់ដារបច្ចេកទេស។

អាស្រ័យហេតុនេះ សូមប្រតិបត្តិករទូរគមនាគមន៍ចល័តទាំងអស់ត្រូវអនុវត្តតាមការណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០

អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០៦៩
អ៊ីមែល : info@mptc.gov.kh